00662066

E50/3/1/13

# នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក/អជតក(០៤)

ភាគីដាក់ឯកសារ: លោក ខៀវ សំផន

ដាក់ជូន: អង្គជំនុំជម្រះតុលាការកំពូល

ភាសាដើម: **ខ្មែរ**

កាលបរិច្ឆេទឯកសារ: ថ្ងៃទី១១ ខែមេសា ឆ្នាំ២០១១

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយសាលាដំបូង សាធារណៈ / Public

ប្រភេទនៃចំណាត់

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**ចម្លើយតប**

---

**ដាក់ដោយ៖**

**សហមេធាវីការពារក្ដីលោក ខៀវ សំផន**

លោក ស សូវាន

លោក Jacques VERGES

លោក Philippe GRECIANO

**ផ្ញើជូន៖**

**អង្គជំនុំជម្រះសាលាកំពូល**

ចៅក្រម គង់ ស្រឹម

ចៅក្រម M. Motoo NOGUCHI

ចៅក្រម សោម សិរីវឌ្ឍ

ចៅក្រម Agnieszka KLONOWIECKA-MILART

ចៅក្រម ស៊ិន រិទ្ធ

ចៅក្រម Chandra Nihal JAYASINGHE

ចៅក្រម យ៉ា ណារិន

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

ឯកសារទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception): 11 / 04 / 2011
ម៉ោង (Time/Heure): 14:55
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

លោក Andrew CAYLEY

# សូមគោរពអង្គជំនុំជម្រះតុលាការកំពូល

## ១. សេចក្តីផ្តើម

១. នៅពីថ្ងៃទី៣ ខែមិនា ឆ្នាំ២០១១ លោក ខៀវ សំផន បានដាក់បណ្តឹងសារទុក្ខប្រឆាំងទៅនឹងសេចក្តីសម្រេច ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១១ ពាក់ព័ន្ធទៅនឹងសំណើសុំដោះលែងរូបលោកឱ្យមានសេរីភាពជាបន្ទាន់។[1]

២. នៅថ្ងៃទី២៥ ខែមិនា ឆ្នាំ២០១១ លោក ខៀវ សំផន ទទួលបានចម្លើយពីសហព្រះរាជអាជ្ញា ដែលឆ្លើយទៅនឹងបណ្តឹងសារទុក្ខរបស់លោក ជាភាសាអង់គ្លេស និងភាសាខ្មែរប៉ុណ្ណោះ។[2] នៅថ្ងៃទី៧ ខែមេសា ឆ្នាំ២០១១ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា លោកមានពេល៥ថ្ងៃ បន្ទាប់ពីថ្ងៃទទួលបានសេចក្តីជូនដំណឹងជាភាសាបារាំង ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០១១[3] ដើម្បីឆ្លើយតប។

៣. នៅក្នុងចម្លើយ សហព្រះរាជអាជ្ញាព្យាយាមពន្យល់ឱ្យ អង្គជំនុំជម្រះតុលាការកំពូលច្រានចោលបណ្តឹងសារទុក្ខរបស់ លោក ខៀវ សំផន។ ក៏ប៉ុន្តែ សហព្រះរាជអាជ្ញាមិនអាចបង្ហាញឱ្យឃើញថា អង្គជំនុំជម្រះសាលាដំបូងមិនបានប្រព្រឹត្តកំហុស ដែលនាំឱ្យសេចក្តីសម្រេចមិនមានសុពលភាពនោះឡើយ។

## ២. ការពិភាក្សា

៤. អង្គជំនុំជម្រះតុលាការកំពូល នឹងមិនបណ្តោយឱ្យខ្លួនភាន់ច្រឡំដោយសារតែអំណះអំណាងរបស់សហព្រះរាជអាជ្ញា ដោយសារតែការបកស្រាយវិធាន ៦៨.៣[4] និងការបំពានទៅលើ

---

[1] បណ្តឹងសារទុក្ខប្រឆាំងនឹងសេចក្តីសម្រេចលើសំណើសុំដោះលែងឱ្យមានសេរីភាពជាបន្ទាន់ ថ្ងៃទី៣ មិនា ២០១១ ឯកសារលេខ E50/3 ("ពាក្យស្នើសុំ")។ សេចក្តីសម្រេចលើសំណើសុំដោះលែងជាបន្ទាន់របស់លោក នួន ជា លោក ខៀវ សំផន អ្នកស្រី អៀង ធីរិទ្ធិ ថ្ងៃទី១៦ កុម្ភៈ ២០១១ ឯកសារលេខ E50 ("សេចក្តីសម្រេច")។

[2] ចម្លើយរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងរបស់លោក ខៀវ សំផន ប្រឆាំងទៅនឹងសេចក្តីសម្រេចលើសំណើសុំដោះលែងឱ្យមានសេរីភាពជាបន្ទាន់ ថ្ងៃទី២៨ ខែមិនា ឆ្នាំ២០១១ E50/3/1/1 ("ចម្លើយ") ។

[3] ចម្លើយរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងរបស់លោក ខៀវ សំផន ប្រឆាំងទៅនឹងដីកាសម្រេចស្តីពីការដោះលែងឱ្យមានសេរីភាពជាបន្ទាន់ ថ្ងៃទី២៨ ខែមិនា ឆ្នាំ២០១១ E50/3/1/1 ("ចម្លើយ") ។

[4] ចម្លើយ កថាខណ្ឌទី៧ ដល់ទី១០

សិទ្ធិទទួលបានការកាត់សេចក្តីប្រកបដោយយុត្តិធម៌នោះឡើយ។[5] ហេតុនេះហើយបានជាដើមបណ្តឹងសារទុក្ខមិននៅអែរអង់តែត្រឹមនោះឡើយ ហើយរក្សាកាន់តែខ្លាំងឡើងៗនូវអំណះអំណាងគ្រប់បែបយ៉ាងដែលបានលើកឡើងកាលពីលើកមុនៗនោះថែមទៀត។

៥. ក៏ប៉ុន្តែ ដើមបណ្តឹងសារទុក្ខបានត្រឹមតែក្រោកតវ៉ាប្រឆាំងនឹងអំពើផ្តេសផ្តាសតាមផ្លូវតុលាការ ឯសហព្រះរាជអាជ្ញាព្យាយាមរំលោភបំពានទៅលើអង្គជំនុំជម្រះតុលាការកំពូលពាក់ព័ន្ធទៅនឹងបទដ្ឋាននៃការត្រួតពិនិត្យ នៅក្នុងបណ្តឹងសារទុក្ខ និងឯករាជ្យភាពនៃវិធាន ៨២ និង៦៣ ៣)នៃវិធានផ្ទៃក្នុង។

## ១) បទដ្ឋាននៃការត្រួតពិនិត្យ និងអំណាចនៃអង្គជំនុំជម្រះតុលាការកំពូល

៦. បើតាមសហព្រះរាជអាជ្ញា វិធាន១០៤ នៃវិធានផ្ទៃក្នុង ("វិធានផ្ទៃក្នុង") ផ្តល់លទ្ធភាពតែមួយគត់ដើម្បីអាចដាក់បណ្តឹងសារទុក្ខភ្លាមៗ ៖ កំហុសឆ្គងជាក់ស្តែងក្នុងការអនុវត្តឆន្ទានុសិទ្ធិនៃអង្គជំនុំជម្រះសាលាដំបូងដែលនាំឱ្យខូចប្រយោជន៍ដល់ដើមបណ្តឹងសារទុក្ខ។[6]

៧. តាមពិតទៅ វិធាន១០៤ នៃវិធានផ្ទៃក្នុង ផ្តល់លទ្ធភាពពីរផ្សេងទៀត ដើម្បីអាចដាក់បណ្តឹងឧទ្ធរណ៍ភ្លាមៗ ៖ មានកំហុសលើអង្គច្បាប់ដែលនាំឱ្យសេចក្តីសម្រេចអស់សុពលភាព ឬក៏ការមានកំហុសនៃអង្គហេតុដែលនាំឱ្យសេចក្តីសម្រេចនោះមានភាពមិនយុត្តិធម៌។ វាជាការគ្រប់គ្រាន់ណាស់ទៅហើយ បើគេអានវិធាន១០៥.២ ដែលបញ្ជាក់ពីមូលហេតុនៃបណ្តឹងសារទុក្ខ ដែលអាចលើកមកនៅក្នុងសេចក្តីប្រកាសបណ្តឹងសារទុក្ខ ក្នុងករណីបណ្តឹងភ្លាមៗដើម្បី ធានាបាននូវអ្វីដែលទើបតែនិយាយនៅខាងដើម។

៨. ដោយលើកឡើងតែការភ័ន្តច្រឡំដែលស្តែងចេញពីការប្រើអំណាចឆន្ទានុសិទ្ធិ ជាមួយនឹងលទ្ធភាពរបស់ចៅក្រមលើបណ្តឹងសារទុក្ខ ដែលយកសម្អាងហេតុរបស់ខ្លួនទៅជំនួសសម្អាងហេតុដែលលើកឡើងនៅក្នុងសេចក្តីសម្រេច[7] សហព្រះរាជអាជ្ញាព្យាយាមបំពានទៅលើតុលាការកំពូល ហើយចោទថា សាលាដំបូងប្រព្រឹត្តកំហុសនៃអង្គហេតុ។

---

[5] ចម្លើយ កថាខណ្ឌទី២៩ ដល់ទី៣១

[6] ចម្លើយ កថាខណ្ឌទី៤

[7] ចម្លើយ កថាខណ្ឌទី៤ ដល់ទី៦ (ផ្នែកទី២)។

៩. ភស្តុតាងស្ថិតនៅត្រង់ថា សហព្រះរាជអាជ្ញា "បានពិនិត្យមើលឡើងវិញម្តងមួយៗ" នូវលក្ខខណ្ឌដែលមានចែងនៅក្នុងវិធាន៦៣.៣ ខ.៤ និងខ.៥ មុននឹងប្រកាសថា អង្គជំនុំជម្រះតុលាការកំពូល "អាចនាំធ្វើការពិនិត្យអង្គហេតុជាថ្មី"។[8]

១០. គេចាំបាច់ត្រូវសង្កេតឃើញថា សហព្រះរាជអាជ្ញាធ្លាប់បានរំឭករួចទៅហើយពីមូលហេតុនៃការឃុំខ្លួនដើមបណ្តឹងសារទុក្ខ ដោយអនុលោមទៅតាម វិធាន៦៣.៣ ខ.៤ នៅអង្គជំនុំជម្រះសាលាដំបូង ហើយសហព្រះរាជអាជ្ញាបានរំឭកពីវិធាន៦៣.៣ ខ.៥ ជាលើកដំបូងនៅក្នុង "ចម្លើយ"។[9] ក៏ប៉ុន្តែ បើតាមវិធាន ១១០ នៃវិធានផ្ទៃក្នុង ៖

> ១. វិសាលភាពនៃបណ្តឹងសារទុក្ខត្រូវកម្រិតត្រឹមបញ្ហា ដែលលើកឡើងក្នុងលិខិតប្តឹងសារទុក្ខ និង តាមលក្ខណៈ សម្បត្តិរបស់អ្នកប្តឹងសារទុក្ខ។
>
> ២. គ្រប់ករណីទាំងអស់ អង្គជំនុំជម្រះតុលាការកំពូល អាចកែប្រែបទចោទប្រកាន់ ដែលអង្គជំនុំជម្រះសាលាដំបូងបានកំណត់ ។ ប៉ុន្តែអង្គជំនុំជម្រះតុលាការកំពូលមិនត្រូវបន្ថែមធាតុផ្សំថ្មី នៃបទល្មើសណាមួយដែលមិនបានដាក់ជូននៅអង្គជំនុំជម្រះសាលាដំបូងដើម្បីសម្រេចនោះទេ។[10]

១១. លើសពីនោះទៅទៀត ក្នុងករណីមានកំហុសនៃអង្គហេតុ ចៅក្រមតុលាការកំពូលចៀសវាងបដិសេធដោយឥតគិតវែងឆ្ងាយនូវការយល់ឃើញរបស់ចៅក្រមសាលាដំបូង ហើយដោយត្រូវយល់ស្របតាមការថ្លឹងថ្លែងលើអង្គហេតុរបស់ចៅក្រមទាំងនោះ អន្តរាគមន៍របស់ចៅក្រមតុលាការកំពូលមានហេតុផលត្រឹមត្រូវតែនៅក្នុងករណីដ៏កម្រប៉ុណ្ណោះ។[11]

១២. ក្នុងករណីជាក់ស្តែងនេះ ដោយស្នើសុំឲ្យអង្គជំនុំជម្រះតុលាការកំពូល ជំនួសមូលហេតុនៅក្នុងសេចក្តីសម្រេចដោយមូលហេតុរបស់ខ្លួន តាមពិតទៅ សហព្រះរាជអាជ្ញាព្យាយាមសុំឲ្យតុលាការកំពូលយកការថ្លឹងថ្លែងលើ**អង្គហេតុរបស់ខ្លួន** ទៅជំនួសលើការថ្លឹងថ្លែងរបស់អង្គជំនុំជម្រះសាលាដំបូងទៅវិញទេ ។

---

[8] ចម្លើយ កថាខណ្ឌទី១៩ ដល់ទី២៨ (ផ្នែកទី៦)

[9] ដីកាសម្រេច កថាខណ្ឌទី១៩ និងទី២០

[10] នៅក្នុងច្បាប់ដើមមិនមានគូសបន្ទាត់ពីក្រោមទេ។

[11] *Zigiranyirazo c. le Procureur*, affaire ICTR-01-73-A សាលដីកា ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០០៩កថាខណ្ឌទី១១

១៣. នៅក្នុងចម្លើយ សហព្រះរាជអាជ្ញាលើកយកឧទាហរណ៍នៅអង្គបុរេជំនុំជម្រះ។[12] ប្រសិនបើអង្គបុរេជំនុំជម្រះអាចយកសម្អាងហេតុរបស់ខ្លួន ទៅជំនួសសម្អាងហេតុដែលលើកឡើងដោយសហចៅក្រមស៊ើបអង្កេតមែន នោះអង្គបុរេជំនុំជម្រះមានចេតនាមិនចង់យកការ"ថ្លឹងថ្លែង"របស់ខ្លួន ទៅជំនួសការថ្លឹងថ្លែងរបស់សហចៅក្រមស៊ើបអង្កេត ដោយលើកហេតុផលថា "ទំហំនៃការត្រួតពិនិត្យរបស់ខ្លួន ត្រូវកម្រិតត្រឹមតែឲ្យដឹងថា តើសហចៅក្រមស៊ើបអង្កេតបានបំពេញកិច្ចការត្រឹមត្រូវនូវអំណាចឆន្ទានុសិទ្ធិរបស់ខ្លួនដែរឬទេ"។ [13]

១៤. ទោះជាក្នុងករណីណាក៏ដោយ ដើមបណ្តឹងសារទុក្ខរំឭកថា លោកបានធ្វើបណ្តឹងសារទុក្ខទៅអង្គជំនុំជម្រះតុលាការកំពូល ដោយមូលហេតុថា អង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តកំហុសនៃអង្គច្បាប់បួនយ៉ាង និងកំហុសមួយដែលចេញពីការប្រើអំណាចឆន្ទានុសិទ្ធិរបស់ខ្លួន។

## ២. វិធាន ៨២ និង៦៣ ៣) នៃវិធានផ្ទៃក្នុង

១៥. ជាក់ស្តែង សហព្រះរាជអាជ្ញាព្យាយាមបិទបាំងកំហុសឆ្គងរបស់អង្គជំនុំជម្រះ ដោយព្យាយាមធ្វើឲ្យគេជឿថា វិធាន ៨២ និង៦៣ ៣) គឺឯករាជ្យពីគ្នា។ សម្រាប់សហព្រះរាជអាជ្ញា ការឃុំខ្លួនដើមបណ្តឹងសារទុក្ខត្រូវបន្តជាស្វ័យប្រវត្តិ ដោយអនុវត្តតាមវិធាន ៨២ ១) "មិនថាការពិចារណាលើកត្តានានាក្នុងអនុវិធាន ៦៣ ៣) វាយ៉ាងណានោះក៏ដោយ" ព្រោះថា វិធាននេះ "មិនតម្រូវឲ្យមានការពិចារណាលើកត្តានានាក្នុងអនុវិធាន ៦៣ ៣)" ទេ។[14]

១៦. ដោយឡែក តាមវិធាន ៨២ ១) និង២) ដែលសហព្រះរាជអាជ្ញាបានលើកឡើង៖

---

[12] ចម្លើយ កថាខណ្ឌទី៤ ដល់ទី៦។

[13] សូមអាន សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចលើសំណើសុំស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុកឯកសាររួម ១២ វិច្ឆិកា ២00៩ D164/3/6 កថាខណ្ឌទី២៥ និងទី២៦ (ក៏មានយោងទៅនឹង កំណត់ត្រាជើងទំព័រលេខ ៩ នៃចម្លើយ ផងដែរ)។

[14] ចម្លើយ កថាខណ្ឌ ១១ ដល់១៤ និង ១៧ គ។

១. ជនជាប់ចោទត្រូវមានសេរីភាពរហូតដល់ពេលមកបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង លើកលែងតែមានការបង្គាប់ឱ្យឃុំខ្លួនបណ្ដោះអាសន្ន ដូច**មានចែងនៅក្នុងវិធានផ្ទៃក្នុងនេះ**។ ក្នុងករណីដែលជនជាប់ចោទត្រូវបានឃុំខ្លួននៅពេលចូលខ្លួនលើកដំបូង នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងជនជាប់ចោទត្រូវស្ថិតនៅក្នុងឃុំដដែលរហូតដល់ពេលសាលក្រមនៃអង្គជំនុំជម្រះសាលាដំបូងត្រូវបានសម្រេចសេចក្ដីលើកលែងតែករណីដែលមានចែងក្នុងអនុវិធាន ២ ខាងក្រោម។

២. គ្រប់ពេលនៃកិច្ចដំណើរការនីតិវិធី អង្គជំនុំជម្រះអាចបង្គាប់ឱ្យដោះលែងជនជាប់ចោទ ឬដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការក្នុងករណីចាំបាច់ ឬបង្គាប់ឱ្យឃុំខ្លួនជនជាប់ចោទបាន**ស្របតាមវិធានផ្ទៃក្នុងនេះ**។ អង្គជំនុំជម្រះសាលាដំបូងត្រូវសម្រេចអំពីបញ្ហានេះ បន្ទាប់ពីបានស្ដាប់ជនជាប់ចោទ មេធាវីជនជាប់ចោទ និងសហព្រះរាជអាជ្ញា។[15]

១៧. ជាក់ស្ដែង ក្នុងកថាខណ្ឌទាំងពីរនេះ ពាក្យ "ដោយអនុលោមតាមវិធានផ្ទៃក្នុងនេះ" យោងទៅលើវិធាន ៦៣ ៣)។ ការបន្តឃុំខ្លួនមិនអាចត្រូវបានបង្គាប់ "ជាស្វ័យប្រវត្តិ" ដោយពុំមានលក្ខខណ្ឌច្បាស់លាស់ និងកំណត់តាមច្បាប់ បានជាដាច់ខាត។

១៨.ម្យ៉ាងទៀត អង្គជំនុំជម្រះសាលាដំបូងបានយល់យ៉ាងច្បាស់អំពីបញ្ហានេះ ដោយបង្គាប់ឱ្យ "បន្តឃុំខ្លួនលោក ខៀវ សំផន ដោយអនុលោមតាមវិធាន ៦៣ ៣) ខ) ៣) នៃវិធានផ្ទៃក្នុង "[16]។ ទង្វើនេះ គឺអង្គជំនុំជម្រះបានប្រព្រឹត្តកំហុសឆ្គងតែមួយប៉ុណ្ណោះ គឺ កំហុសឆ្គងក្នុងការលើកយកលក្ខខណ្ឌតែមួយនៃទម្ងន់នៃទោសទណ្ឌ ដើម្បីយកមកសម្អាងក្នុងសេចក្ដីសម្រេចរបស់ខ្លួន ដូចដែលសហព្រះរាជអាជ្ញាខ្លួនឯងទទួលស្គាល់ផងដែរនោះ។[17] កំហុសឆ្គងនេះធ្វើឱ្យសេចក្ដីសម្រេចពុំមានសុពលភាព ដែលតម្រូវឱ្យមានការកែប្រែវិញ ព្រោះថាការឃុំខ្លួនមិនមានអំណះអំណាងផ្លូវច្បាប់ ហើយថា សេរីភាព គឺជាគោលការណ៍។[18]

---

[15] នៅក្នុងច្បាប់ដើមមិនមានគូសបន្ទាត់ពីក្រោមទេ។

[16] សេចក្ដីសម្រេច កថាខណ្ឌ ៤០។

[17] ចម្លើយ កថាខណ្ឌ ១៦។

[18] បណ្ដឹងសារទុក្ខ កថាខណ្ឌ ១៧ ដល់២៣។

E50/3/1/3

# ហេតុដូច្នេះ

១៩. សូមឱ្យអង្គជំនុំជម្រះតុលាការកំពូល មេត្តា៖

- បដិសេធចោលនូវអំណះអំណាងទាំងអស់របស់សហព្រះរាជអាជ្ញា
- យល់ស្របតាមអំណះអំណាងកន្លងមកទាំងអស់របស់ដើមបណ្តឹងសាទុក្ខ
- ដោះលែងលោក ខៀវ សំផន ឱ្យមានសេរីភាព ជាបន្ទាន់។

## រក្សាសិទ្ធិកែប្រែគ្រប់យ៉ាង

## និងដើម្បីយុត្តិធម៌

| | | | |
|---|---|---|---|
| | មេធាវី ស សូវាន | ភ្នំពេញ | [signature] |
| [initials] | មេធាវី Jacques VERGÈS | ប៉ារីស | [signature] |
| [initials] | មេធាវី Philippe GRECIANO | ប៉ារីស | [signature] |
| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |